# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៨/១៩ គ.ម.ក./ប្រ.ក

# ប្រកាស
# ស្តីពី
# ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩

## ស ម្រេ ច

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនសមភាគីកណ្ដាល ឈ្មួញជើង-សាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ព្រមទាំងបុគ្គលពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅបញ្ញត្តិពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនសមភាគីកណ្ដាល ឈ្មួញជើង-សាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ព្រមទាំងបុគ្គលពាក់ព័ន្ធដែលធ្វើសកម្មភាពអាជីវកម្មជួញដូរឧបករណ៍និស្សន្ទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនសមភាគីកណ្ដាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ព្រមទាំងបុគ្គលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធរបស់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមាននៅក្នុងប្រកាសស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត÷** សំដៅដល់ក្រុមហ៊ុនសមភាគីកណ្ដាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**គណនីឆន្ទានុសិទ្ធិ÷** សំដៅដល់គណនីជួញដូររបស់អតិថិជនដែលឈ្មួញជើងសាឧបករណ៍និស្សន្ទមានឆន្ទានុសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចចិត្តក្នុងការជួញដូរឧបករណ៍និស្សន្ទ ដោយមិនចាំបាច់ទទួលបានបញ្ជាពីអតិថិជន។

**បញ្ជាមិនមែនអតិថិជន÷** សំដៅដល់បញ្ជាទិញ ឬលក់ឧបករណ៍និស្សន្ទរបស់សហកម្មសិទ្ធិករ អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

**បុគ្គលិកជាន់ខ្ពស់÷** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងអភិបាល។

**ភ្នាក់ងារ**÷ សំដៅដល់ឈ្មួញជើងសាឧបករណ៍និស្សន្ទដែលតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយក្រុមហ៊ុនសមភាគីកណ្តាលដើម្បីធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនសមភាគីកណ្តាលនោះ។

**អនុក្រឹត្យ**÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ជំពូកទី ២
## គោលការណ៍អាជីវកម្ម

### ប្រការ ៥.- គោលការណ៍ទូទៅនៃអាជីវកម្ម

ដើម្បីឱ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាអតិបរមា និងធានាឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវក្នុងការជួញដូរឧបករណ៍និស្សន្ទ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវគោរពតាមគោលការណ៍ទូទៅនៃអាជីវកម្មដូចខាងក្រោម÷

១-ស្វែងរកព័ត៌មានរបស់អតិថិជនអំពីស្ថានភាពហិរញ្ញវត្ថុ បទពិសោធន៍វិនិយោគ និងគោលដៅវិនិយោគរបស់អតិថិជនពាក់ព័ន្ធនឹងសេវាកម្មដែលត្រូវផ្តល់ឱ្យ។

២-ធ្វើសកម្មភាព និងអាជីវកម្មប្រកបដោយជំនាញ ការយកចិត្តទុកដាក់ និងសេចក្តីព្យាយាម។

៣-បង្ហាញព័ត៌មានជាសារវន្តដែលពាក់ព័ន្ធនៅពេលធ្វើប្រតិបត្តិការជាមួយអតិថិជន។

៤-បំពេញកាតព្វកិច្ចយ៉ាងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងថែរក្សាសាច់ប្រាក់ និង/ឬទ្រព្យសម្បត្តិរបស់អតិថិជនឱ្យបានល្អ។

៥-ចៀសវាងនូវទំនាស់ផលប្រយោជន៍ជាមួយអតិថិជន។ ក្នុងករណីមិនអាចចៀសវាងបាន ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវដោះស្រាយជូនអតិថិជនប្រកបដោយយុត្តិធម៌។

៦-ធ្វើសកម្មភាព និងអាជីវកម្មប្រកបដោយភាពស្មោះត្រង់ យុត្តិធម៌ និងដើម្បីផលប្រយោជន៍អតិថិជននិងសុចរិតភាពទីផ្សារ។

៧-មាន និងប្រើប្រាស់ធនធាន និងនីតិវិធីប្រកបដោយប្រសិទ្ធភាពដែលចាំបាច់សម្រាប់ប្រកបអាជីវកម្ម។

៨-មានបុគ្គលិកជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងការធ្វើឱ្យក្រុមហ៊ុនរក្សាឱ្យបាននូវស្តង់ដានៃការអនុវត្តនិងការគោរពតាមនីតិវិធីសមស្រប។

៩-គោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដើម្បីលើកកម្ពស់ផលប្រយោជន៍អតិថិជន និងសុចរិតភាពទីផ្សារ។

## ជំពូកទី ៣
## ព័ត៌មានអំពីអតិថិជន

**ប្រការ ៦.- ការបើកគណនីជួញដូរ**

អតិថិជនអាចបើកគណនីជួញដូរឧបករណ៍និស្សន្ទបាននៅឈ្មួញជើងសាឧបករណ៍និស្សន្ទ។

នៅពេលបើកគណនីជួញដូរជូនអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ÷

១-បំពេញកាតព្វកិច្ចតាមច្បាប់ក្នុងការសិក្សាឱ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន អនុលោមតាមប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ និងបំពេញទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

២-ពន្យល់ខ្លឹមសារនិងបំពេញកិច្ចព្រមព្រៀងអតិថិជន និងចុះកិច្ចព្រមព្រៀងជាមួយអតិថិជន ដោយអនុលោមតាមប្រការ ៩ នៃប្រកាសនេះ។

៣-ទទួលសេចក្តីប្រកាសទទួលស្គាល់ហានិភ័យពីអតិថិជនដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

៤-ពន្យល់លម្អិតដល់អតិថិជននូវនីតិវិធីនៃការដាក់ ដក ផ្ទេរ និងទូទាត់សាច់ប្រាក់ អនុលោមតាមច្បាប់បទប្បញ្ញត្តិ គោលការណ៍ណែនាំ ឬការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវមានយន្តការច្បាស់លាស់ ដើម្បីធានាថារាល់ប្រតិបត្តិការបើកគណនីជួញដូរ ការគ្រប់គ្រងប្រតិបត្តិការគណនី និងការផ្តល់ប្រឹក្សាវិនិយោគលើឧបករណ៍និស្សន្ទជូនអតិថិជន ត្រូវបានធ្វើឡើងដោយភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

ការអនុញ្ញាតលើការបើកគណនីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានរក្សាទុកក្នុងក្រុមហ៊ុន។

ឈ្មួញជើងសាឧបករណ៍និស្សន្ទមិនត្រូវបើកគណនីអនាមិក ឬគណនីក្លែងក្លាយ ឬគណនីឆន្ទានុសិទ្ធិ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវទិញ ឬលក់ឧបករណ៍និស្សន្ទជំនួសអតិថិជនតាមតែបញ្ជាទិញ-លក់របស់អតិថិជនប៉ុណ្ណោះ។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវពាក់អាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនៅរាល់ពេលបំពេញការងារ និងមានទំនាក់ទំនងជាមួយអតិថិជន។

**ប្រការ ៧.- គោលការណ៍ស្គាល់អតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវមានគោលការណ៍ស្គាល់អតិថិជនដែលត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន និងត្រូវមាននិទ្ទេសអប្បបរមាដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់គោលការណ៍ស្គាល់អតិថិជនជូន **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នៅពេលមានការកែប្រែគោលការណ៍ស្គាល់អតិថិជននេះ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូន **គ.ម.ក.** នូវគោលការណ៍ស្គាល់អតិថិជនថ្មីដោយភ្ជាប់មកជាមួយនូវការបញ្ជាក់លើចំណុចដែលត្រូវបានកែប្រែក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

**ប្រការ ៨.- ការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អតិថិជនអនុលោមតាមគោល-ការណ៍ស្គាល់អតិថិជន និង/ឬគោលនយោបាយ និងយន្តការលើការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម មុននឹងបើកគណនីជួញដូរជូនអតិថិជន។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ÷

១-កំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អតិថិជនដោយផ្អែកលើឯកសារ ទិន្នន័យ ឬព័ត៌មានដែលជឿជាក់បាន និងមានប្រភពឯករាជ្យ។

២-ផ្ទៀងផ្ទាត់ថាបុគ្គលដែលធ្វើសកម្មភាពជំនួសអតិថិជនត្រូវបានអនុញ្ញាត និងត្រូវកំណត់ និងផ្ទៀង-ផ្ទាត់អត្តសញ្ញាណរបស់បុគ្គលនោះ។

៣-កំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អត្ថគាហកៈ ដោយផ្អែកលើឯកសារ ទិន្នន័យ ឬព័ត៌មានដែលជឿជាក់បាន និងមានប្រភពឯករាជ្យ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធ្វើកំណត់ត្រាអំពីអត្តសញ្ញាណរបស់អតិថិជន និងរក្សាទុកឱ្យបានត្រឹមត្រូវ។

ករណីឈ្មួញជើងសាឧបករណ៍និស្សន្ទមិនអាចអនុវត្តតាមប្រការនេះ ឈ្មួញជើងសាឧបករណ៍និស្សន្ទមិនត្រូវបើកគណនីជួញដូរជូនអតិថិជននោះទេ។

**ប្រការ ៩.- កិច្ចព្រមព្រៀងអតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវមានទម្រង់កិច្ចព្រមព្រៀងអតិថិជនដែលមាននិទ្ទេសអប្បបរមាដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូន **គ.ម.ក.** នូវទម្រង់កិច្ចព្រម-ព្រៀងអតិថិជនឱ្យបានយ៉ាងតិច ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនដាក់ឱ្យប្រើប្រាស់។ នៅពេលមានការកែប្រែទម្រង់កិច្ចព្រមព្រៀងអតិថិជននេះ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូន **គ.ម.ក.** នូវទម្រង់កិច្ចព្រម-ព្រៀងអតិថិជនថ្មីដោយភ្ជាប់មកជាមួយនូវការបញ្ជាក់លើចំណុចដែលត្រូវបានកែប្រែឱ្យបានយ៉ាងតិច ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនដាក់ឱ្យប្រើប្រាស់។

កិច្ចព្រមព្រៀងអតិថិជនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាត្រឹមត្រូវរវាងអតិថិជន និងឈ្មួញជើងសាឧបករណ៍និស្សន្ទ។

មុនចុះហត្ថលេខាជាមួយអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវពន្យល់លម្អិតដល់អតិថិជននូវខ្លឹមសារនៃកិច្ចព្រមព្រៀង ប្រភេទនៃបញ្ជាទិញ-លក់ វិធីសាស្ត្រនៃការជួញដូរ លក្ខខណ្ឌជួញដូរទៅតាមផលិតផលឧបករណ៍និស្សន្ទនីមួយៗដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងហានិភ័យដែលអាចកើតមាន។

**ប្រការ ១០.- ការផ្តល់ប្រឹក្សាវិនិយោគលើឧបករណ៍និស្សន្ទ**

ការផ្តល់ប្រឹក្សាវិនិយោគលើឧបករណ៍និស្សន្ទជូនអតិថិជនត្រូវ ÷

១- ធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល។

២- ធ្វើឡើងដោយផ្អែកលើព័ត៌មានដែលផ្តល់ឲ្យដោយអតិថិជន ហើយត្រូវមានហេតុផលជាមូលដ្ឋានឆ្លុះបញ្ចាំងនូវព័ត៌មានគោលដូចមានកំណត់ក្នុងកថាខណ្ឌទី ២ នៃប្រការនេះ។

មុនពេលផ្តល់ប្រឹក្សាវិនិយោគ ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវស្វែងយល់ពីអតិថិជន ដើម្បីទទួលបាននូវព័ត៌មានដូចខាងក្រោម÷

១- ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីត្រូវការរបស់អតិថិជន។

២- គោលដៅវិនិយោគរបស់អតិថិជន។

៣- ឥរិយាបទអតិថិជនចំពោះហានិភ័យដែលអាចកើតមាន។

៤- បទពិសោធន៍ និងចំណេះដឹងនៃការវិនិយោគរបស់អតិថិជន។

ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ប្រឹក្សាវិនិយោគជូនអតិថិជនតែលើប្រភេទឧបករណ៍និស្សន្ទដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** របស់ក្រុមហ៊ុនសមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទនោះជាភ្នាក់ងារ។

## ជំពូកទី ៤

## ការជួញដូរឧបករណ៍និស្សន្ទ

**ប្រការ ១១.- បញ្ជាទិញ-លក់**

ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទអាចអនុវត្តបញ្ជាទិញ- លក់របស់អតិថិជនក្នុងនាមអតិថិជនបាន លុះត្រាតែអតិថិជននោះមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ។

បញ្ជាទិញ- លក់អាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ, ជាសម្លេង, ជាសារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។ នៅពេលទទួលបញ្ជាអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ឯកសារជាលាយលក្ខណ៍អក្សរ, ថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីផ្ទៀងផ្ទាត់បញ្ជារបស់អតិថិជន។ កំណត់ត្រានៃបញ្ជានោះត្រូវបង្ហាញឈ្មោះរបស់អតិថិជន, លេខគណនីជួញដូរ, ព័ត៌មានលម្អិតនៃបញ្ជា និងកាលបរិច្ឆេទនិងពេលវេលានៃការដាក់បញ្ជាជាដើម។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវមានវិធានការសមស្រប ដើម្បីចៀសវាងស្ថានភាពដែលបញ្ជាមិនអាចត្រូវបានអនុវត្ត ដោយសារកត្តាមិនប្រក្រតីនៃប្រព័ន្ធអេឡិកត្រូនិក ឬមធ្យោបាយផ្សេងទៀត ក្រៅពីមធ្យោបាយជួបផ្ទាល់ជាមួយអតិថិជន។

## ប្រការ ១២.- បុគ្គលដែលមានសិទ្ធិបញ្ជា

ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវទទួលបញ្ជាតែពីបុគ្គលដែលមានសិទ្ធិដូចខាងក្រោម ÷

១-អតិថិជនជាម្ចាស់គណនី។

២-តំណាងដែលអតិថិជនបានជ្រើសរើសជាលាយលក្ខណ៍អក្សរនៅពេលបើកគណនីជួញដូរ ឬតំណាងដែលត្រូវបានជ្រើសរើសដោយអតិថិជននៅពេលបន្ទាប់ទៀតតាមលិខិតផ្ទេរសិទ្ធិ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្អាកប្រតិបត្តិការជួញដូររបស់អតិថិជន និងត្រូវជូនដំណឹងភ្លាមដល់អតិថិជន ក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាទិញ-លក់ ប្រើប្រាស់ព័ត៌មានរបស់អតិថិជនដើម្បីដាក់បញ្ជាទិញ-លក់។

## ប្រការ ១៣.- ការហាមឃាត់ការទទួលបញ្ជាដែលផ្ទុយនឹងច្បាប់

ក្នុងករណីការបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទធ្វើឡើងតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមិនត្រូវទទួលបញ្ជាដូចខាងក្រោម÷

១-ពេលភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដឹងថាការជួញដូររបស់អតិថិជនល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២-ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមានមូលដ្ឋានបង្ហាញថា អតិថិជនមិនអាចទូទាត់ការជួញដូរបានដោយពិនិត្យលើសមតុល្យសាច់ប្រាក់នៅក្នុងគណនីជួញដូររបស់អតិថិជន។

## ប្រការ ១៤.- ការបញ្ជូនបញ្ជារបស់អតិថិជន

នៅពេលភ្នាក់ងារជើងសាឧបករណ៍និស្សន្ទទទួលបញ្ជាពីអតិថិជន ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវបញ្ជូនបញ្ជានោះភ្លាម និងក្នុងលក្ខខណ្ឌប្រសើរបំផុតទៅកាន់ក្រុមហ៊ុនសមភាគីកណ្ដាលតាមលក្ខខណ្ឌនៃបញ្ជា និងមិនត្រូវបង្គរបញ្ជា ដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ឬដាក់បញ្ជាជាកញ្ចប់។

ឈ្មួញជើងសាឧបករណ៍និស្សន្ទតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវបញ្ជូនបញ្ជារបស់អតិថិជនតាមលំដាប់រៀងនៃបញ្ជាដែលក្រុមហ៊ុនបានទទួល។ បញ្ជារបស់អតិថិជនត្រូវមានអាទិភាពលើបញ្ជាក្នុងគណនីជួញដូរផ្ទាល់របស់ក្រុមហ៊ុន ឬបញ្ជាក្នុងគណនីមិនមែនអតិថិជន។

## ប្រការ ១៥.- ការរក្សាម៉ាជីន

មុនអនុញ្ញាតឱ្យអតិថិជនជួញដូរឧបករណ៍និស្សន្ទ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវត្រួតពិនិត្យ និងធានាថាអតិថិជនបានដាក់តម្កល់ម៉ាជីនដំបូងតាមកម្រិតឡេវើរ៉េច និងបានគោរពតាមកម្រិតម៉ាជីនរក្សា ម៉ាជីនខល និងម៉ាជីនទូទាត់ដូចដែលបានកំណត់ក្នុងវិធានប្រតិបត្តិការឧបករណ៍និស្សន្ទដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

ករណីកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបញ្ជូនម៉ាជីនខលទៅអតិថិជនតាមរយៈមធ្យោបាយដែលទទួលការយល់ព្រមជាមុនពីអតិថិជនដូចជា លិខិតជាលាយលក្ខណ៍អក្សរ ទូរសារ ទូរសព្ទ អ៊ីមែល ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀត ដោយតម្រូវឱ្យអតិថិជនដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនីក្នុងរយៈពេលជាក់លាក់មួយ ដើម្បីឱ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនកើនឡើងដល់លក្ខខណ្ឌតម្រូវ។

ករណីឈ្មួញជើងសាឧបករណ៍និស្សន្ទមិនបានទទួលសាច់ប្រាក់បន្ថែមពីអតិថិជនក្នុងរយៈពេលដែលបានកំណត់ ឈ្មួញជើងសាឧបករណ៍និស្សន្ទមានសិទ្ធិដូចខាងក្រោម÷

១-បដិសេធការដាក់បញ្ជាទិញ-លក់ឧបករណ៍និស្សន្ទបន្ថែមរបស់អតិថិជន។

២-បិទរាល់ស្ថានភាពជួញដូរឧបករណ៍និស្សន្ទទាំងអស់ ឬមួយផ្នែករបស់អតិថិជន។

## ប្រការ ១៦.- វិធានប្រតិបត្តិការឧបករណ៍និស្សន្ទ

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវមានវិធានប្រតិបត្តិការឧបករណ៍និស្សន្ទតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.** និងត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងប្រើប្រាស់ និង/ឬកែប្រែវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនសមភាគីកណ្តាលដែលមានបំណងកែប្រែវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតកែប្រែមក **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវអត្ថបទ និងសេចក្តីពន្យល់អំពីគម្រោងកែប្រែវិធានប្រតិបត្តិការឧបករណ៍និស្សន្ទនោះ។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់នៅ **គ.ម.ក.** ចំនួន ១០០.០០០ (មួយរយពាន់) រៀល នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ ឬកែប្រែវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ។

វិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្តាលដែលទទួលបានការអនុញ្ញាត ត្រូវមានប្រសិទ្ធភាពជាកិច្ចសន្យារវាងក្រុមហ៊ុនសមភាគីកណ្តាល និងភ្នាក់ងាររបស់ខ្លួន។

## ប្រការ ១៧.- ការស្នើសុំការអនុញ្ញាតលើប្រភេទឧបករណ៍និស្សន្ទសម្រាប់ការជួញដូរ

មុនដាក់ប្រភេទឧបករណ៍និស្សន្ទណាមួយឱ្យជួញដូរនៅក្នុងទីផ្សារឧបករណ៍និស្សន្ទ ក្រុមហ៊ុនសមភាគីកណ្តាលត្រូវស្នើសុំការអនុញ្ញាតជាមុនពី **គ.ម.ក.**។ ការដាក់ពាក្យស្នើសុំការអនុញ្ញាតនេះត្រូវភ្ជាប់មកជាមួយនូវសេចក្តីព្រាងវិធានប្រតិបត្តិការឧបករណ៍និស្សន្ទថ្មីដោយបញ្ចូលនូវបុគ្គលិកលក្ខណៈនៃប្រភេទឧបករណ៍និស្សន្ទដែលស្នើសុំថ្មីនោះ រួមទាំងឯកសារផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** អាចអញ្ជើញក្រុមហ៊ុនសមភាគីកណ្តាលមកបំភ្លឺបន្ថែមលើប្រភេទឧបករណ៍និស្សន្ទដែលស្នើសុំថ្មី និងសេចក្តីព្រាងវិធានប្រតិបត្តិការឧបករណ៍និស្សន្ទថ្មី។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតនៅ **គ.ម.ក.** ចំនួន ៤០.០០០ (សែសិបពាន់) រៀល សម្រាប់ប្រភេទឧបករណ៍និស្សន្ទមួយដែលត្រូវយកមកជួញដូរ។

## ប្រការ ១៨.- ការស្នើសុំការអនុញ្ញាតលើការតភ្ជាប់ និងការផ្តាច់ប្រព័ន្ធជួញដូរជាមួយក្រុមហ៊ុនសមភាគីកណ្តាល

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតភ្ជាប់ ផ្តាច់ ឬផ្លាស់ប្តូរការតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយក្រុមហ៊ុនសមភាគីកណ្តាលណាមួយ។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវធានាថាការតភ្ជាប់ ឬការផ្តាច់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយឈ្មួញជើងសាឧបករណ៍និស្សន្ទណាមួយ ត្រូវបានធ្វើឡើងអនុលោមតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវរបស់ **គ.ម.ក.** និងត្រូវជូនដំណឹងភ្លាមមក **គ.ម.ក.** អំពីការតភ្ជាប់ ឬការផ្តាច់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទនោះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងផ្លាស់ប្តូរ ឬបន្ថែមវេទិកាជួញដូរឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតនៅ **គ.ម.ក.** ចំនួន ១០០.០០០ (មួយរយពាន់) រៀល សម្រាប់រាល់ការផ្លាស់ប្តូរ ឬការតភ្ជាប់ប្រព័ន្ធជួញដូរបន្ថែម ការផ្លាស់ប្តូរ ឬការបន្ថែមវេទិកាជួញដូរឧបករណ៍និស្សន្ទ។

## ប្រការ ១៩.- ការបែងចែកកំណត់ត្រាដាច់ដោយឡែកពីគ្នា

ក្រុមហ៊ុនមូលបត្រទទួលបានការអនុញ្ញាតធ្វើអាជីវកម្មជាក្រុមហ៊ុនសមភាគីកណ្តាល និង/ឬឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវធ្វើការបែងចែកកំណត់ត្រាដាច់ដោយឡែកពីគ្នារវាងគណនីជួញដូរមូលបត្រ និងគណនីជួញដូរឧបករណ៍និស្សន្ទ។

## ប្រការ ២០.- ការឃ្លាំមើលប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវមានយន្តការឃ្លាំមើល និងធ្វើការឃ្លាំមើលប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ ដើម្បីកំណត់អត្តសញ្ញាណប្រតិបត្តិការជួញដូរដែលជាប់សង្ស័យថាមានភាពមិនប្រក្រតី។

ការកំណត់អត្តសញ្ញាណប្រតិបត្តិការជួញដូរដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ត្រូវបានធ្វើឡើងដោយគិតបញ្ចូលនូវព័ត៌មានមួយចំនួនដូចជា របៀបនៃការជួញដូរ ភាពញឹកញាប់នៃការបើក-បិទស្ថានភាពជួញដូរ និងទំហំនៃការជួញដូរ ជាដើម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់យន្តការឃ្លាំមើលប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទជូន **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នៅពេលមានការកែប្រែយន្តការឃ្លាំមើលប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនេះ ក្រុមហ៊ុន

ទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវយន្តការឃ្លាំមើលប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទថ្មីដោយភ្ជាប់មកជាមួយនូវការបញ្ជាក់លើចំណុចដែលត្រូវបានកែប្រែក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

**ប្រការ ២១.- ភារកិច្ចរាយការណ៍បន្ទាន់ជូន គ.ម.ក.**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវរាយការណ៍ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនអគ្គនាយកនៃ **គ.ម.ក.** នៅពេល÷

១-មានការផ្អាកការជួញដូរឧបករណ៍និស្សន្ទណាមួយ។

២-មានភាពមិនប្រក្រតីនៃការជួញដូរឧបករណ៍និស្សន្ទណាមួយ។

៣-ទទួលបានព័ត៌មានដែលអាចបណ្តាលឱ្យមានផលប៉ះពាល់លើឧបករណ៍និស្សន្ទណាមួយ ឬទីផ្សារឧបករណ៍និស្សន្ទទាំងមូល។

៤-អគ្គនាយកនៃ **គ.ម.ក.** ស្នើឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតផ្តល់ព័ត៌មានពាក់ព័ន្ធ។

## ជំពូកទី ៥
## ព័ត៌មានសម្រាប់អតិថិជន

**ប្រការ ២២.- ការផ្តល់ព័ត៌មានអំពីក្រុមហ៊ុន**

នៅពេលមានទំនាក់ទំនងជាមួយអតិថិជន ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូនអតិថិជននូវព័ត៌មានសមស្រប និងគ្រប់គ្រាន់អំពីអាជីវកម្មរបស់ក្រុមហ៊ុន អាជ្ញាបណ្ណ/ការអនុញ្ញាតដែលទទួលបានពី **គ.ម.ក.** ព័ត៌មានទំនាក់ទំនងលម្អិត សេវាកម្មដែលអាចផ្តល់ជូនអតិថិជន អត្តសញ្ញាណនិងស្ថានភាពរបស់និយោជិតរបស់ក្រុមហ៊ុនដែលអតិថិជនអាចទាក់ទងជាមួយ និងអត្តសញ្ញាណរបស់ក្រុមហ៊ុនសមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទនោះបានតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយ។

**ប្រការ ២៣.- ការផ្តល់វិធានប្រតិបត្តិការឧបករណ៍និស្សន្ទ**

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវផ្តល់ជូនឈ្មួញជើងសាឧបករណ៍និស្សន្ទដែលជាភ្នាក់ងាររបស់ខ្លួននូវវិធានប្រតិបត្តិការឧបករណ៍និស្សន្ទដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូន និងពន្យល់អតិថិជនរបស់ខ្លួននូវវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទនោះបានតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយ។

**ប្រការ ២៤.- ការផ្តល់សេចក្តីបញ្ជាក់អំពីការជួញដូរ**

ក្នុងករណីការបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទធ្វើឡើងតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូនអតិថិជនភ្លាមបន្ទាប់ពីការអនុវត្តបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទរបស់អតិថិជន នូវសេចក្តីបញ្ជាក់អំពីការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន ដោយមាននូវព័ត៌មានអប្បបរមាដូចជា ប្រភេទឧបករណ៍និស្សន្ទដែលបានជួញដូរ ថ្លៃ ចំនួនឯកតាជួញដូរ ការបើក ឬបិទស្ថានភាពជួញដូរជាដើម។

**ប្រការ ២៥.- ការបង្ហាញផលប្រយោជន៍**

ក្នុងករណីមុនពេល ឬនៅពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទបានទទួល ឬនឹងទទួលបានផលប្រយោជន៍ជារូបិយវត្ថុ និង/ឬមិនមែនជារូបិយវត្ថុពីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តី សម្រាប់ចែកចាយប្រភេទឧបករណ៍និស្សន្ទណាមួយ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនោះត្រូវបង្ហាញព័ត៌មានអំពីផលប្រយោជន៍នោះទៅអតិថិជន។

**ប្រការ ២៦.- របាយការណ៍សាច់ប្រាក់អតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្តល់ជូនអតិថិជននូវរបាយការណ៍សាច់ប្រាក់អតិថិជន ប្រសិនបើមានសំណើពីអតិថិជន។

**ប្រការ ២៧.- ការផ្អាកប្រតិបត្តិការអាជីវកម្ម**

ករណី **គ.ម.ក.** បានផ្អាកអាជីវកម្មរបស់ក្រុមហ៊ុនសមភាគីកណ្តាលមួយផ្នែក ឬទាំងស្រុង ក្រុមហ៊ុនសមភាគីកណ្តាលត្រូវជូនដំណឹងភ្លាមដល់ភ្នាក់ងាររបស់ខ្លួន និងអតិថិជនតាមរយៈភ្នាក់ងាររបស់ខ្លួន និងត្រូវចាត់វិធានការសមស្រប ដើម្បីធានាថាប្រតិបត្តិការដែលមានជាមួយភ្នាក់ងារ និងអតិថិជនត្រូវបានដោះស្រាយសមស្រប។

ករណី **គ.ម.ក.** បានផ្អាកអាជីវកម្មរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទមួយផ្នែក ឬទាំងស្រុង ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុនសមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទបានតភ្ជាប់ប្រព័ន្ធជួញដូរជាមួយ និងអតិថិជន និងត្រូវចាត់វិធានការសមស្របដើម្បីធានាថាប្រតិបត្តិការដែលមានជាមួយក្រុមហ៊ុនសមភាគីកណ្តាល និងអតិថិជនត្រូវបានដោះស្រាយសមស្រប។

ករណី **គ.ម.ក.** បានផ្អាកសកម្មភាពរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទមួយផ្នែក ឬទាំងស្រុង ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជូនដំណឹងដល់អតិថិជន និងត្រូវចាត់វិធានការសមស្របដើម្បីធានាថាប្រតិបត្តិការដែលមានជាមួយអតិថិជន ត្រូវបានដោះស្រាយសមស្រប។

## ជំពូកទី ៦

## សាច់ប្រាក់របស់អតិថិជន

**ប្រការ ២៨.- គណនីសាច់ប្រាក់អតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបើកគណនីសាច់ប្រាក់ដែលមានឈ្មោះ "គណនីសាច់ប្រាក់អតិថិ-ជនឧបករណ៍និស្សន្ទ" នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីរក្សាទុកសាច់ប្រាក់របស់អតិថិជនតែប៉ុណ្ណោះ ក្នុងគោលដៅទូទាត់ក្នុងប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធ្វើ និងរក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវនិងច្បាស់លាស់នូវសាច់ប្រាក់របស់អតិថិជននីមួយៗ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជូនដំណឹងមក **គ.ម.ក.** អំពីការបើកគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ ដោយភ្ជាប់មកជាមួយនូវកិច្ចព្រមព្រៀងបើកគណនី និង/ឬឯកសារពាក់ព័ន្ធក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃបើកគណនីនោះ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទមិនត្រូវដាក់សាច់ប្រាក់អតិថិជន នៅក្នុងគណនីណាផ្សេងពីគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទឡើយ និងមិនត្រូវរក្សាទុកសាច់ប្រាក់អតិថិជនលាយឡំជាមួយសាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុន។

### ប្រការ ២៩.- ការដាក់សាច់ប្រាក់អតិថិជន

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដាក់សាច់ប្រាក់អតិថិជនសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ ដោយគោរពតាមយន្តការដូចខាងក្រោម÷

១-អតិថិជនដាក់សាច់ប្រាក់ ឬផ្ទេរសាច់ប្រាក់ចូលគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទដោយបញ្ជាក់ឱ្យបានច្បាស់ពីលេខគណនីជួញដូររបស់អតិថិជន និង/ឬអត្តសញ្ញាណរបស់អតិថិជន គោល-ដៅនៃការដាក់ ឬផ្ទេរសាច់ប្រាក់ និងទំហំសាច់ប្រាក់។

២-ក្នុងករណីអតិថិជនដាក់សាច់ប្រាក់តាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដាក់សាច់ប្រាក់អតិថិជនដែលទទួលបានក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទក្នុងថ្ងៃធ្វើការដែលទទួលបានសាច់ប្រាក់នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ពីលេខគណនីជួញដូររបស់អតិថិជន និង/ឬអត្តសញ្ញាណរបស់អតិថិជន គោលដៅនៃការដាក់សាច់ប្រាក់ និងទំហំសាច់ប្រាក់។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជូនដំណឹងជាបន្ទាន់ដល់អតិថិជនអំពីទំហំសាច់ប្រាក់ កាលបរិច្ឆេទនិងពេលវេលានៃការដាក់សាច់ប្រាក់ លេខគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ និងឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៣-នៅពេលទទួលបានសាច់ប្រាក់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវផ្ទៀងផ្ទាត់ និងបញ្ជាក់ពីព័ត៌មានរបស់អតិថិជនមុននឹងដាក់ ឬផ្ទេរសាច់ប្រាក់ចូលគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ។

៤-បន្ទាប់ពីបានដាក់សាច់ប្រាក់ចូលគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទរួច ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវជូនដំណឹងដល់ឈ្មួញជើងសាឧបករណ៍និស្សន្ទដោយបញ្ជាក់ឱ្យបានច្បាស់ពីលេខគណនីជួញដូររបស់អតិថិជន និង/ឬអត្តសញ្ញាណរបស់អតិថិជន និងទំហំសាច់ប្រាក់។

៥-ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធ្វើការផ្ទៀងផ្ទាត់ព័ត៌មានរបស់អតិថិជន មុនបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូររបស់អតិថិជន។

៦-ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជូនដំណឹងដល់អតិថិជន អំពីការបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូររបស់អតិថិជនដោយបញ្ជាក់ពីលេខគណនីជួញដូររបស់អតិថិជន អត្តសញ្ញាណរបស់អតិថិជន កាលបរិច្ឆេទ និងទំហំសាច់ប្រាក់ដែលបានបញ្ចូល។

## ប្រការ ៣០.- ការដកសាច់ប្រាក់អតិថិជន

ឈ្មួញជើងសាឧបករណ៍និស្សន្ទអាចដកសាច់ប្រាក់អតិថិជនចេញពីគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទបាន ក្នុងលក្ខខណ្ឌដើម្បី៖

១-ទូទាត់ទៅឱ្យបុគ្គលណាមួយដែលមានសិទ្ធិទទួល ក្នុងក្របខ័ណ្ឌនៃការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។

២-ទូទាត់ថ្លៃសេវា កម្រៃជើងសាឧបករណ៍និស្សន្ទ និងបន្ទុកចំណាយផ្សេងទៀត ដែលអតិថិជនត្រូវបង់។

៣-ទូទាត់ទៅឱ្យបុគ្គល ឬគណនីផ្សេងយោងតាមសំណើជាលាយលក្ខណ៍អក្សររបស់អតិថិជន។

៤-ធ្វើការទូទាត់ដែលតម្រូវដោយច្បាប់ ឬ **គ.ម.ក.**។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដកសាច់ប្រាក់ជូនអតិថិជនតាមសំណើរបស់អតិថិជន និងត្រូវពិនិត្យសមតុល្យក្នុងគណនីជួញដូររបស់អតិថិជន និងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ ព្រមទាំងផ្ទៀងផ្ទាត់ព័ត៌មានរបស់អតិថិជន និងទំហំសាច់ប្រាក់ដែលស្នើសុំដក។

ដើម្បីអាចដកសាច់ប្រាក់ជូនអតិថិជនបាន ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដាក់សំណើដកសាច់ប្រាក់ទៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយបញ្ជាក់ពីលេខគណនីជួញដូររបស់អតិថិជន ព័ត៌មានអតិថិជនដែលមានសិទ្ធិដកសាច់ប្រាក់ និងទំហំសាច់ប្រាក់ដែលស្នើសុំដកបាន។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវកែតម្រូវសមតុល្យសាច់ប្រាក់នៅក្នុងគណនីជួញដូររបស់អតិថិជនបន្ទាប់ពីបានពិនិត្យ និងផ្ទៀងផ្ទាត់សមតុល្យ សកម្មភាពជួញដូរក្នុងគណនីជួញដូររបស់អតិថិជន និងចំនួនសាច់ប្រាក់ដែលបានស្នើសុំដក។

## ប្រការ ៣១.- ការទូទាត់សាច់ប្រាក់អតិថិជន

ដើម្បីសម្រួលដល់ការទូទាត់សាច់ប្រាក់អតិថិជនក្នុងការជួញដូរឧបករណ៍និស្សន្ទ ក្រុមហ៊ុនសមាភាគីកណ្ដាលត្រូវបើកគណនីសាច់ប្រាក់សម្រាប់ទូទាត់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវផ្តល់ជូន **គ.ម.ក.** នូវព័ត៌មាននៃគណនីសាច់ប្រាក់នោះ។

នៅពេលស្ថានភាពជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជនត្រូវបានបិទដោយអតិថិជនខ្លួនឯង ឬដោយឈ្មួញជើងសាឧបករណ៍និស្សន្ទក្នុងករណីកម្រិតម៉ាជីនធ្លាក់ដល់ម៉ាជីនទូទាត់ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវគណនាសាច់ប្រាក់ខាតបង់ ឬចំណេញរបស់អតិថិជន ថ្លៃសេវា និងកម្រៃផ្សេងទៀត ដោយធ្វើការផ្ទៀងផ្ទាត់ផងដែរជាមួយក្រុមហ៊ុនសមភាគីកណ្ដាល។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដាក់សំណើទៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីផ្ទេរសាច់ប្រាក់ដែលអតិថិជនត្រូវបង់ពីគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ ទៅគណនីសាច់ប្រាក់របស់ក្រុមហ៊ុនសមភាគីកណ្ដាល។ ក្រុមហ៊ុនសមភាគីកណ្ដាលត្រូវផ្ទេរសាច់ប្រាក់ដែលអតិថិជនត្រូវទទួល ពីគណនីសាច់ប្រាក់របស់ក្រុមហ៊ុនសមភាគីកណ្ដាលទៅគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធានាថាសាច់ប្រាក់របស់អតិថិជននីមួយៗនៅក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ឬ ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិដែលបំពេញលក្ខខណ្ឌតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣២.- ការធ្វើកំណត់ត្រាលំហូរសាច់ប្រាក់អតិថិជន**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ÷

១-ធ្វើកំណត់ត្រាលើគ្រប់ប្រតិបត្តិការនៅក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ។

២-ផ្ទៀងផ្ទាត់ប្រចាំថ្ងៃរវាងកំណត់ត្រាដូចមានចែងក្នុងចំណុចទី ១ នៃប្រការនេះ និងកំណត់ត្រារបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវជូនដំណឹងមក **គ.ម.ក.** ក្នុងករណីមានភាពមិនប្រក្រតីពីការផ្ទៀងផ្ទាត់។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវរៀបចំយន្តការនៃការគ្រប់គ្រង និងការផ្ទៀងផ្ទាត់សាច់ប្រាក់អតិថិជននីមួយៗ និងដាក់ជូន **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ឱ្យអនុវត្ត។

## ជំពូកទី ៧

## ទំនាស់ផលប្រយោជន៍

**ប្រការ ៣៣.- ការហាមឃាត់លើការជំរុញឱ្យធ្វើការជួញដូរច្រើនហួសហេតុ**

ឈ្មួញជើងសាឧបករណ៍និស្សន្ទមិនត្រូវជំរុញឱ្យអតិថិជនជួញដូរឧបករណ៍និស្សន្ទច្រើនហួសហេតុលើសពីភាពចាំបាច់សម្រាប់ផលប្រយោជន៍អតិថិជន ដោយគិតពិចារណាលើកត្តាដូចខាងក្រោម÷

១-កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗដែលបង់ដោយអតិថិជន។

២-គោលដៅវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ សេចក្ដីត្រូវការ និងស្ថានភាពជាក់ស្ដែងរបស់អតិថិជន។

៣-កម្រិតនៃការយល់ដឹងរបស់អតិថិជនលើហានិភ័យដែលអាចកើតមានឡើងចំពោះការជួញដូរឧបករណ៍និស្សន្ទ ដោយផ្អែកលើចំណេះដឹង និង/ ឬបទពិសោធន៍វិនិយោគរបស់អតិថិជន។

**ប្រការ ៣៤.- ការហាមឃាត់លើការផ្តល់ប្រឹក្សាយោបល់ និងការធ្វើប្រតិបត្តិការ**

ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលមានផលប្រយោជន៍ជាសារវន្តក្នុងប្រតិបត្តិការជាមួយ ឬសម្រាប់អតិថិជន ឬមានទំនាក់ទំនងដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬសក្តានុពលពាក់ព័ន្ធនឹងប្រតិបត្តិការនោះ មិនត្រូវផ្តល់ប្រឹក្សាយោបល់ និងធ្វើប្រតិបត្តិការនោះឡើយ លើកលែងតែឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទបានបង្ហាញផលប្រយោជន៍ជាសារវន្ត ឬទំនាស់ផលប្រយោជន៍នោះទៅអតិថិជន និងបានចាត់វិធានការសមស្របដើម្បីធានានូវការប្រតិបត្តិយុត្តិធម៌ចំពោះអតិថិជន។

## ជំពូកទី ៨

## ការផ្សព្វផ្សាយពាណិជ្ជកម្ម

**ប្រការ ៣៥.- ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការដាក់បង្ហាញព័ត៌មាន**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលមានបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ឬដាក់បង្ហាញព័ត៌មាន ត្រូវរៀបចំខ្លឹមសារ និងវិធីសាស្ត្របង្ហាញសមស្រប ដើម្បីឱ្យអតិថិជនអាចទទួលបានព័ត៌មានចាំបាច់ និងមានប្រយោជន៍សម្រាប់ការជួញដូរឧបករណ៍និស្សន្ទ ឬសម្រាប់ធ្វើការសម្រេចចិត្តវិនិយោគលើឧបករណ៍និស្សន្ទ។

ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការដាក់បង្ហាញព័ត៌មានដូចមានចែងនៅក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១-មិនត្រូវមានព័ត៌មានដែលមានលក្ខណៈមិនពិត នាំឱ្យយល់ខុស បោកបញ្ឆោត ឬប៉ះពាល់ដល់អ្នកដទៃ។

២-មិនត្រូវបង្ហាញវេទិកាជួញដូរ ប្រភេទនៃឧបករណ៍និស្សន្ទ ប្រភេទបញ្ជាទិញ-លក់ កម្រិតម៉ាជីនដំបូង កម្រិតឡេវើរ៉េច កម្រិតម៉ាជីនរក្សា កម្រិតម៉ាជីនទូទាត់ នីតិវិធីដាក់ ដក ផ្ទេរ និងទូទាត់សាច់ប្រាក់ និងព័ត៌មានផ្សេងទៀតនៅក្នុងវិធានប្រតិបត្តិការឧបករណ៍និស្សន្ទដែលមិនទាន់ទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

៣-មិនត្រូវថ្លែងបញ្ជិតបញ្ចៀងពាក់ព័ន្ធនឹង ឬធានាឱ្យបាននូវប្រាក់ចំណេញពីការជួញដូរឧបករណ៍និស្សន្ទ។

៤-មិនត្រូវមានព័ត៌មានដែលផ្ទុយពីច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ **គ.ម.ក.**។

៥-មានពាក្យដាស់តឿនអំពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។

៦- មានប្រភពព័ត៌មានឱ្យបានច្បាស់លាស់ដែលមានលក្ខណៈបច្ចុប្បន្នភាព និងគួរឱ្យទុកចិត្តក្នុងករណីប្រើប្រាស់ ឬយោងព័ត៌មានដែលផ្តល់ឱ្យដោយបុគ្គលផ្សេង។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវមានគេហទំព័រ លេខទូរសព្ទ និងអ៊ីមែលផ្ទាល់របស់ក្រុមហ៊ុនសម្រាប់ទំនាក់ទំនងជាមួយអតិថិជន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវថតចម្លង និងរក្សាទុកឯកសារនៃការផ្សព្វផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណ និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀត។

## ជំពូកទី ៩
## ធនធានរបស់ក្រុមហ៊ុន

### ប្រការ ៣៦.- បុគ្គលិកត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវតែងតាំងនិយោជិតដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ ដើម្បីបំពេញមុខងារត្រួតពិនិត្យផ្ទៃក្នុង និងត្រូវធានាថាការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងស្របតាមគោលនយោបាយស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវមានផែនការត្រួតពិនិត្យផ្ទៃក្នុង និងធ្វើការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងតិច ១ (មួយ) ដង ក្នុងមួយឆមាស និងត្រូវរៀបចំ និងរក្សាទុករបាយការណ៍នៃការត្រួតពិនិត្យផ្ទៃក្នុងនោះ។

ករណីរកឃើញការបំពានណាមួយធ្វើឡើងដោយបុគ្គលិកជាន់ខ្ពស់ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ឬនិយោជិត ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវចាត់វិធានការភ្លាមៗចំពោះអ្នកប្រព្រឹត្តទាំងនោះ។

### ប្រការ ៣៧.- បុគ្គលិកជំនាញផ្នែកច្បាប់

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវមានបុគ្គលិកជំនាញផ្នែកច្បាប់ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១- ផ្តល់ប្រឹក្សា និងត្រួតពិនិត្យឱ្យបានទៀងទាត់នូវអនុលោមភាពតាមច្បាប់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន និងការអនុវត្តការងាររបស់នាយកប្រតិបត្តិ និងផ្នែកផ្សេងៗ។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវធ្វើ និងរក្សាទុកនូវកំណត់ត្រាពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សា និងការត្រួតពិនិត្យនេះ។

២- រក្សាទុក និងត្រួតពិនិត្យឡើងវិញនូវនីតិវិធីអនុលោមភាពតាមច្បាប់សម្រាប់ផ្នែកនីមួយៗរបស់ក្រុមហ៊ុន។

៣- ត្រួតពិនិត្យ និង/ឬស៊ើបអង្កេតភាពមិនប្រក្រតីទាំងឡាយដែលកើតមាននៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុន។ រាល់លទ្ធផលដែលបានរកឃើញត្រូវរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ។ ក្នុងករណីចាំបាច់ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវជូនដំណឹង និង/ឬប្រឹក្សាជាមួយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន និង/ឬ **គ.ម.ក.**។

៤-ទទួលបន្ទុករៀបចំសៀវភៅមគ្គុទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់និយោជិតរបស់ក្រុមហ៊ុន។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសៀវភៅមគ្គុទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។

៥-ផ្តល់ការបណ្តុះបណ្តាល ធ្វើបច្ចុប្បន្នកម្ម និង/ឬផ្តល់ប្រឹក្សាដល់ក្រុមហ៊ុន និង/ឬសមាជិកនៃក្រុមប្រឹក្សាភិបាលអំពីបញ្ហាអនុលោមភាពតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការអភិវឌ្ឍបទប្បញ្ញត្តិ។ រាល់ការបណ្តុះបណ្តាលត្រូវធ្វើឡើងយ៉ាងតិច ៣ (បី) ដង ក្នុងមួយឆ្នាំ និងរក្សាទុកនូវរាល់កំណត់ត្រាពាក់ព័ន្ធនឹងការបណ្តុះបណ្តាលនោះ។

៦-ត្រួតពិនិត្យ និងដោះស្រាយទំនាស់ផលប្រយោជន៍ផ្សេងៗ និងបណ្តឹងរបស់អតិថិជន។

៧-ផ្តល់ប្រឹក្សាលើបញ្ហាអនុលោមភាពតាមច្បាប់ពាក់ព័ន្ធនឹងការជួញដូរដែលធ្វើឡើងដោយនិយោជិតបុគ្គលិកជាន់ខ្ពស់ និងអភិបាលរបស់ក្រុមហ៊ុន។

៨-តួនាទី និងភារកិច្ចផ្សេងទៀតដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ១០
## ការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

### ប្រការ ៣៨.- ការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

បុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវ÷

១-គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវហានិភ័យពាក់ព័ន្ធនឹងអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដោយរួមបញ្ចូលទាំងការវាយតម្លៃឱ្យបានទៀងទាត់លើដំណើរការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន។

២-យល់ដឹងអំពីប្រភេទនៃអាជីវកម្ម នីតិវិធីត្រួតពិនិត្យផ្ទៃក្នុង និងគោលនយោបាយស្តីពីការកំណត់ហានិភ័យរបស់ក្រុមហ៊ុន។

៣-យល់ដឹងឱ្យច្បាស់នូវសិទ្ធិអំណាច មុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន។

**គ.ម.ក.** អាចពិចារណាលើកម្រិតនៃការទទួលខុសត្រូវក្នុងក្រុមហ៊ុន ភារកិច្ចត្រួតពិនិត្យ និងកម្រិតនៃការត្រួតពិនិត្យ ឬការដឹងរបស់បុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធនឹងការខកខានរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបុគ្គលដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលិកជាន់ខ្ពស់នោះ ក្នុងការគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ១១
## អនុលោមភាពតាមច្បាប់

## ប្រការ ៣៩.- ការជួញដូររបស់អភិបាល និងនិយោជិត

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវមានគោលនយោបាយស្តីពីការជួញដូរឧបករណ៍និស្សន្ទរបស់អភិបាល និងនិយោជិត។

ករណីអភិបាល និងនិយោជិតត្រូវបានអនុញ្ញាតឱ្យជួញដូរឧបករណ៍និស្សន្ទក្នុងគណនីផ្ទាល់ខ្លួន គោល-នយោបាយដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវមានចំណុចជាអប្បបរមាដូចខាងក្រោម÷

១-លក្ខខណ្ឌដែលអនុញ្ញាតឱ្យអភិបាល និងនិយោជិតជួញដូរឧបករណ៍និស្សន្ទក្នុងគណនីផ្ទាល់ខ្លួនបាន។

២-ការតម្រូវឱ្យអភិបាល និងនិយោជិតកំណត់អត្តសញ្ញាណគណនីពាក់ព័ន្ធទាំងអស់ និងរាយការណ៍ទៅអភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ ឬនាយកប្រតិបត្តិ។ គណនីពាក់ព័ន្ធត្រូវរាប់បញ្ចូលទាំងគណនីរបស់កូនដែលជាអនីតិជន និងគណនីដែលនិយោជិតនោះអាចទទួលបានផលប្រយោជន៍។

៣-ការតម្រូវឱ្យអភិបាល និងនិយោជិតបើកគណនី និងជួញដូរតាមរយៈភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ។

៤-ប្រតិបត្តិការក្នុងគណនីផ្ទាល់របស់អភិបាល និងនិយោជិត និងក្នុងគណនីពាក់ព័ន្ធត្រូវកត់ត្រាដាច់ដោយឡែកពីគ្នា និងត្រូវបែងចែកឱ្យបានច្បាស់លាស់នៅក្នុងកំណត់ត្រារបស់ក្រុមហ៊ុន។

៥-ប្រតិបត្តិការក្នុងគណនីផ្ទាល់របស់អភិបាល និងនិយោជិត និងក្នុងគណនីពាក់ព័ន្ធត្រូវរាយការណ៍ទៅ និងត្រួតពិនិត្យ តាមដានយ៉ាងសកម្មពីអភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ ឬនាយកប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់ណាមួយដែលមិនមានផលប្រយោជន៍នៅក្នុងប្រតិបត្តិការ និងត្រូវធានាថាការបញ្ជា ឬប្រតិបត្តិការជួញដូរទាំងនេះមិនប៉ះពាល់ដល់ផលប្រយោជន៍របស់អតិថិជនរបស់ក្រុមហ៊ុន។

## ប្រការ ៤០.- បណ្តឹងរបស់អតិថិជន

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវ÷

១-ដោះស្រាយបណ្តឹងរបស់អតិថិជន និងឆ្លើយតបឱ្យទាន់ពេលវេលា និងត្រឹមត្រូវ អនុលោមតាមគោលនយោបាយ និងនីតិវិធីនៃការដោះស្រាយបណ្តឹងរបស់អតិថិជនរបស់ក្រុមហ៊ុន។

២-ណែនាំអតិថិជនអំពីនីតិវិធីបន្ទាប់ ក្នុងករណីបណ្តឹងនោះមិនត្រូវបានដោះស្រាយដោយក្រុមហ៊ុន ឬករណីអតិថិជនមិនពេញចិត្តទៅនឹងការសម្រេចរបស់ក្រុមហ៊ុន។

## ប្រការ ៤១.- ការទទួលខុសត្រូវលើសកម្មភាពរបស់និយោជិត

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវទទួលខុសត្រូវលើសកម្មភាពរបស់និយោជិតដែលធ្វើឡើងក្នុងក្របខ័ណ្ឌបំពេញការងារឱ្យក្រុមហ៊ុន។

## ប្រការ ៤២.- ការទទួលខុសត្រូវលើសកម្មភាពរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ÷

១-ត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើសកម្មភាពរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលបំពេញមុខងារក្នុងនាមឈ្មួញជើងសាឧបករណ៍និស្សន្ទនោះ។

២-បង្កើត រក្សា និងតម្រូវឱ្យអនុវត្តនីតិវិធីជាលាយលក្ខណ៍អក្សរទាក់ទងនឹងការប្រព្រឹត្តនៃភ្នាក់ងារជើងសាឧបករណ៍និស្សន្ទរបស់ខ្លួន។

៣-ទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលកើតចេញពីសកម្មភាពរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាតពីឈ្មួញជើង-សាឧបករណ៍និស្សន្ទ ដោយរាប់បញ្ចូលទាំងសកម្មភាពដែលទទួលបានការអនុញ្ញាតដោយតុណ្ហីភាពដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដឹង ឬគួរតែដឹងថាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនោះបានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធសកម្មភាពទាំងនោះ។

## ប្រការ ៤៣.- ការរក្សាទុកកំណត់ត្រាពាក់ព័ន្ធនឹងអាជីវកម្ម

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវរក្សា និងថែទាំរាល់កំណត់ត្រា ឯកសារ និងបញ្ជិកាគណនេយ្យរបស់ខ្លួន ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ នៅទីកន្លែងដែលមានសុវត្ថិភាព និងត្រូវជូនដំណឹងមក **គ.ម.ក.** អំពីទីកន្លែងរក្សាទុកនោះ។

## ប្រការ ៤៤.- ការអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវ÷

១-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ខ្លួន និងបទប្បញ្ញត្តិជាធរមាន។

២-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន និងប្រាកដថាភ្នាក់ងាររបស់ខ្លួនគោរពតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ។

៣-មានយន្តការតាមដាន និងធ្វើការតាមដានការប្រព្រឹត្តរបស់ភ្នាក់ងារ។ ករណីសង្ស័យ ឬរកឃើញថាភ្នាក់ងារបាន ឬកំពុងប្រព្រឹត្តផ្ទុយពីច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ ឬវិធានប្រតិបត្តិការឧបករណ៍និស្សន្ទក្រុមហ៊ុនសមភាគីកណ្តាលត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូន **គ.ម.ក.**។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ÷

១-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្តាលដែលឈ្មួញជើងសាឧបករណ៍និស្សន្ទនោះជាភ្នាក់ងារ និងបទប្បញ្ញត្តិជាធរមាន។

២-ប្រាកដថាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទរបស់ខ្លួន គោរពតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ។

៣-មានយន្តការតាមដាន និងធ្វើការតាមដានការប្រព្រឹត្តរបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទរបស់ខ្លួន។ ករណីសង្ស័យ ឬរកឃើញថាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទបាន ឬកំពុងប្រព្រឹត្តផ្ទុយពីច្បាប់

បទប្បញ្ញត្តិពាក់ព័ន្ធ ឬវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវរាយ-ការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូន **គ.ម.ក.**។

## ប្រការ ៤៥.- ការប្រព្រឹត្តខុសពីវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ

ប្រសិនបើក្រុមហ៊ុនសមភាគីកណ្ដាលពិនិត្យឃើញថាភ្នាក់ងារដែលមានកាតព្វកិច្ចអនុវត្តតាម ឬស្ថិតនៅក្រោមការតម្រូវឱ្យអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាល មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រុមហ៊ុនសមភាគីកណ្ដាលនោះអាចតម្រូវឱ្យភ្នាក់ងារនោះអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទ ក្នុងរយៈពេលមួយជាក់លាក់តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ។

ប្រសិនបើ **គ.ម.ក.** ពិនិត្យឃើញថាឈ្មួញជើងសាឧបករណ៍និស្សន្ទដែលមានកាតព្វកិច្ចអនុវត្តតាម ឬស្ថិតនៅក្រោមការតម្រូវឱ្យអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនសមភាគីកណ្ដាលចាត់វិធានការអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាល លើឈ្មួញជើងសាឧបករណ៍និស្សន្ទនោះ ក្នុងរយៈពេលមួយជាក់លាក់តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ។

ប្រសិនបើឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានការជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ នៃប្រការនេះ មិនអនុវត្តតាមការជូនដំណឹងនោះក្នុងរយៈពេលមួយជាក់លាក់ដែលកំណត់ក្នុងសេចក្តីជូនដំណឹង ឈ្មួញជើងសាឧបករណ៍និស្សន្ទនោះត្រូវបានចាត់ទុកថា បំពានលើវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាល ហើយក្រុមហ៊ុនសមភាគីកណ្ដាលអាចចាត់វិធានការអនុវត្តតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាល ឬដាក់ពាក្យស្នើសុំមក **គ.ម.ក.** ដើម្បីចាត់វិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនសមភាគីកណ្ដាលត្រូវសហការជាមួយអគ្គនាយកនៃ **គ.ម.ក.** ឬមន្ត្រីរបស់ **គ.ម.ក.** ដែលទទួលសិទ្ធិពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីអនុវត្តមុខងាររបស់ខ្លួនចំពោះភ្នាក់ងាររបស់ខ្លួន។

ប្រសិនបើក្រុមហ៊ុនសមភាគីកណ្ដាលធ្វើការព្រមាន ឬចាត់វិធានការខាងវិន័យផ្សេងៗចំពោះភ្នាក់ងារក្រុមហ៊ុនសមភាគីកណ្ដាលនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុននឹងចាត់វិធានការអនុវត្ត ដោយបញ្ជាក់ឈ្មោះភ្នាក់ងារនោះ និងត្រូវបញ្ជាក់មូលហេតុនៃការចាត់វិធានការទាំងនោះ។

ប្រសិនបើក្រុមហ៊ុនសមភាគីកណ្ដាលសង្ស័យថាមានភ្នាក់ងារណាមួយបានប្រព្រឹត្ត ឬកំពុងប្រព្រឹត្ត ឬមានបំណងនឹងប្រព្រឹត្តបំពានលើវិធានប្រតិបត្តិការឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនសមភាគីកណ្ដាល ឬលក្ខខណ្ឌណាមួយរបស់ច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ក្រុមហ៊ុនសមភាគីកណ្ដាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់អំពីការសង្ស័យនោះមក **គ.ម.ក.**។

**ប្រការ ៤៦.- វិធានការខាងវិន័យ**

អគ្គនាយកនៃ **គ.ម.ក.** អាចពិនិត្យឡើងវិញ ទៅលើវិធានការខាងវិន័យ ដែលដាក់ចេញដោយក្រុមហ៊ុនសមភាគីកណ្តាលស្របតាមវិធានប្រតិបត្តិការឧបករណ៍និស្សន្ទចំពោះភ្នាក់ងារ។ បន្ទាប់ពីផ្តល់ឱកាសឱ្យក្រុមហ៊ុនសមភាគីកណ្តាល និងភ្នាក់ងារដែលទទួលរងការខូចខាតដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនសមភាគីកណ្តាលធ្វើការបំភ្លឺ អគ្គនាយកនៃ **គ.ម.ក.** អាចយល់ព្រម ឬច្រានចោលសេចក្តីសម្រេចនោះ ដោយផ្អែកលើច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះក៏ដោយ ប្រសិនបើក្រុមហ៊ុនសមភាគីកណ្តាលនោះខកខាន ឬមិនអាចចាត់វិធានការខាងវិន័យសមស្របចំពោះភ្នាក់ងារ អគ្គនាយកនៃ **គ.ម.ក.** អាចព្រមាន ឬចាត់វិធានការខាងវិន័យផ្សេងៗ ដែលកំណត់ដោយ **គ.ម.ក.** ចំពោះភ្នាក់ងារ ប៉ុន្តែអគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសដល់ភ្នាក់ងារដែលត្រូវទទួលរងវិធានការខាងវិន័យនោះ និងក្រុមហ៊ុនសមភាគីកណ្តាល ធ្វើការឆ្លើយបំភ្លឺជាមុនសិន។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**ប្រការ ៤៧.- ពិន័យអន្តរការណ៍**

ដោយមិនគិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទព្រមទាំងបុគ្គលពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រការ ៥, កថាខណ្ឌទី ២ កថាខណ្ឌទី ៣ កថាខណ្ឌទី ៥ និងកថាខណ្ឌទី ៦ នៃប្រការ ៦, កថាខណ្ឌទី ៤ នៃប្រការ ៨, កថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃប្រការ ១០, ប្រការ ១១, ប្រការ ១២, ប្រការ ១៤, ប្រការ ១៥ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ឬប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងប្រការ ៤៨ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី ២៥០.០០០.០០០ (ពីររយហាសិបលាន) រៀល។

ក្នុងករណីមិនរាងចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលពិន័យអន្តរការណ៍ទ្វេរដង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលរងពិន័យអន្តរការណ៍ពី **គ.ម.ក.** និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ១ កថាខណ្ឌទី ២ ឬកថាខណ្ឌទី ៣ នៃប្រការនេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ ៤៨.- ទណ្ឌកម្មរដ្ឋបាល**

ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ព្រមទាំងបុគ្គលពាក់ព័ន្ធដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ កថាខណ្ឌទី ៤ និងកថាខណ្ឌទី ៧ នៃប្រការ ៦, ប្រការ ៧, កថាខណ្ឌទី ១ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃប្រការ ៨, ប្រការ ៩, កថាខណ្ឌទី ២ នៃប្រការ ១០, ប្រការ ១៣, កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ១៦, កថាខណ្ឌទី ១ នៃប្រការ ១៧, កថាខណ្ឌទី ១ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃប្រការ ១៨, ប្រការ ១៩, ប្រការ ២០, ប្រការ ២១, ប្រការ ២២, ប្រការ ២៣, ប្រការ ២៤, ប្រការ ២៥, ប្រការ ២៦, ប្រការ ២៧, ប្រការ ២៨, ប្រការ ២៩, ប្រការ ៣០, ប្រការ ៣១, ប្រការ ៣២, ប្រការ ៣៣, ប្រការ ៣៤, ប្រការ ៣៥, ប្រការ ៣៦, ប្រការ ៣៧, កថាខណ្ឌទី ១ នៃប្រការ ៣៨, ប្រការ ៣៩, ប្រការ ៤០, ប្រការ ៤១, ប្រការ ៤២, ប្រការ ៤៣, ប្រការ ៤៤ ឬកថាខណ្ឌទី ៣ កថាខណ្ឌទី ៤ កថាខណ្ឌទី ៥ និងកថាខណ្ឌទី ៦ នៃប្រការ ៤៥ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលពី **គ.ម.ក.** តាមកថាខណ្ឌទី ២ នៃប្រការនេះ។

អគ្គនាយកនៃ **គ.ម.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ការព្រមាន ឬដាស់តឿន។

២-ការដឹកនាំកែតម្រង់។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់គុណវុឌ្ឍិ។

៥-ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់គុណវុឌ្ឍិ។

៦-ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់គុណវុឌ្ឍិ។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

### ប្រការ ៤៩.- គោលការណ៍ណែនាំ

អគ្គនាយកនៃ **គ.ម.ក.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

### ប្រការ ៥០.- បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

### ប្រការ ៥១.- ការអនុវត្ត

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥១
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ